គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (គ.ប.ស.យ)

Committee For Free And Fair Elections In Cambodia (COMFREL)

ទីស្នាក់ការកណ្តាល ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ទឹកល្អក់ ១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

Central Office: #138, St. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.

ខុមហ្វ្រែល COMFREL

P.O. Box 1145, Tel: (855) 23 884 150/12 942 019, Fax: (855) 23 883 750 E-mail: comfrel@online.com.kh, comfrel@comfrel.org or comfreladmin@online.com.kh, Site : www.comfrel.org



គណៈកម្មាធិការនាយក
BOARD OF DIRECTORS

1. លោក ធន សារាយ
Mr. THUN Saray
ប្រធានគណៈកម្មាធិការនាយក
និងជាប្រធាន ADHOC

2. លោក សុក សំអឿន
Mr. SOK Sam Oeun
អនុប្រធានគណៈកម្មាធិការនាយក
និងជានាយក CDP

3. លោក យឹម ប៉ូ
Mr. YIM Po អគ្គហេរញ្ញិក
និងជានាយក CCPCR

4. អ្នកស្រី ស៊ុន ចាន់សែន
Mrs. SUN Chansen សមាជិកា
និងជាប្រធាន KYA

5. លោក យង់ គិមអេង
Mr. YONG Kim Eng សមាជិក
និងជានាយក PDP-Center

6. លោក មុំ សារិន
Mr. MOM Sarin សមាជិកា
និងជានាយក HRCDO

7. អ្នកស្រី ទីវ សារាយេត
Ms. TIV Sarayet សមាជិកា
និងជាសហនាយិកា WMC

8. កញ្ញា សយ សារា វឌ្ឍនី
Miss. SAY Sara Vathany
សមាជិកា
និងជានាយិកា CWCC

9. លោក គីម សុវណ្ណ
Mr. KIM Sovann សមាជិក
និងជានាយក VIGILANCE

10. នាយក LAC (NA)

11. នាយក KKKHRO (NA)

12. អ្នកស្រី ពឹង យក់ហៀប
Ms. PEUNG Yok Hiep សមាជិកា
ជាឥស្សរជន Dignitary

13. លោក សឹន សែត
Mr. SEN Set សមាជិក
ជាឥស្សរជន Dignitary


ស.ប្រ.ភ.ព/លេខ ១០/១០ គ.ប.ស.យ/អ.ភ

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## លទ្ធផលវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព ក្នុងខេត្ត ព្រៃវែង

*ភ្នំពេញ, ថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០១០*

ម្ចាស់ឆ្នោតនៅខេត្តព្រៃវែងប្រមាណ ៨០នាក់ ក្នុងនោះមាន ស្ត្រី ២២នាក់ មកពីសហគមន៍ជីផ្លី កសិករ អង្គការមិនមែនរដ្ឋាភិបាលនានា អាជីវករ/ពាណិជ្ជករ មន្ត្រីរាជការ សិស្ស/និស្សិត ដែលមកពីស្រុកផ្សេងៗគ្នា និងក្រុងក្នុងខេត្តព្រៃវែង បានបង្ហាញពីការពេញចិត្តច្រើនទៅលើការអនុវត្តន៍ការងារ របស់មន្ត្រីជាប់ឆ្នោតក្នុងការអនុវត្តន៍លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពក្នុងខេត្តព្រៃវែង បើទោះបីជាចំនុចនៃលក្ខខណ្ឌសន្ទស្សន៍ភាគច្រើនមិនត្រូវបានអនុវត្ត ឬអនុវត្តបានតិចតួចក៏ដោយ។

សន្ទស្សន៍សំខាន់ៗជាច្រើនមិនត្រូវបានមន្ត្រីជាប់ឆ្នោត រាជរដ្ឋាភិបាល និងអាជ្ញាធរបានបំពេញទាល់តែសោះ ឬបានធ្វើតិចតួច ដូចជាសុំអោយរាជរដ្ឋាភិបាលជួយបង្កើតរោងចក្រកាត់ដេរ [ នៅខេត្តព្រៃវែង ] និងជួយបង្កើនប្រាក់បៀវត្សដល់កម្មករោងចក្រអោយបានយ៉ាងតិចចំនួន ១០០ ដុល្លារក្នុងមួយខែឡើងទៅ។

ហើយសន្ទស្សន៍ខ្លះ ដែលម្ចាស់ឆ្នោតវាយតំលៃថា បានធ្វើខ្លះៗមានដូចជា ការកាត់បន្ថយរាល់បទល្មើសសង្គម ការរកទីផ្សារសម្រាប់សហគមន៍ និងការបង្កើតសហគមន៍ចិញ្ចឹមសត្វ ការជួសជុលផ្លូវ ការដាក់អំពូលភ្លើងលើដងវិថី និងការតម្លើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការ ។

ទោះបីយ៉ាងណាក្នុងចំណោមលក្ខខណ្ឌសន្ទស្សន៍ទាំងអស់ មានលក្ខខណ្ឌសន្ទស្សន៍តែមួយគត់ដែលម្ចាស់ឆ្នោតភាគច្រើនបានវាយតម្លៃថា បានអនុវត្តស្ទើរតែទាំងស្រុងទាក់ទងទៅនឹងការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ។

អ្នកតំណាងរាស្ត្រ **សៅ រ៉ានី** បានមានប្រសាសន៍ថា ការមិនទាន់បានបំពេញ [ លក្ខខណ្ឌសន្ទស្សន៍មួយចំនួន ] ដែលលើកឡើងដោយម្ចាស់ឆ្នោតក្នុងខេត្ត ដោយសារការខ្វះការយកចិត្តទុកដាក់ពីអាជ្ញាធរមូលដ្ឋាន។ ដូច្នេះគណៈអភិបាលខេត្ត ក្រុមប្រឹក្សាខេត្តនៅពេលប្រជុំត្រូវលើកឡើងពីបញ្ហាដែលកើតមាន ហើយសុំអោយចាត់វិធានការជាបន្ទាន់ ។

តំណាងរាស្ត្រ **អ៊ូ ច័ន្ទឫទ្ធិ** បានសន្យាថា នឹងជំរុញអោយរាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវលើការបំពេញលក្ខខណ្ឌសន្ទស្សន៍ ដូចជាការបង្ក្រាបបទល្មើសពាក់ព័ន្ធអំពើពុករលួយ។

ឯកឧត្តម **ទេព បូរី** សមាជិកក្រុមប្រឹក្សាខេត្តព្រៃវែង បានសន្យាថា នឹងពាំនាំជូនក្រុមប្រឹក្សាខេត្តក៏ដូចជាគណៈអភិបាលខេត្ត ដើម្បីបន្តដោះស្រាយ និងអនុវត្តសន្ទស្សន៍ដែលមិនទាន់បានបំពេញ។

ការវាយតម្លៃនេះ ម្ចាស់ឆ្នោតធ្វើការផ្តល់ពិន្ទុទៅលើការបំពេញ/សម្រេចបានទៅលើចំនុចនីមួយៗដែលម្ចាស់ឆ្នោត បានធ្វើការទាមទារកាលពី ខែកញ្ញា ឆ្នាំ២០០៩ ដោយឱ្យពិន្ទុ "ពិន្ទុ ១ សំរាប់ការមិនបានធ្វើទាល់តែសោះ ឬបានធ្វើតិចតួច(ច្រើនបំផុតត្រឹម ២០%)" "ពិន្ទុ ២ សំរាប់ការបានធ្វើខ្លះ (២១%-៤០%)" "ពិន្ទុ ៣ សំរាប់ការបានធ្វើមធ្យម ឬបានធ្វើពាក់កណ្តាល (៤១%-៦០%)" "ពិន្ទុ ៤ សំរាប់ការបានធ្វើច្រើន (៦១%-៨០%)" និង "ពិន្ទុ ៥ សំរាប់ការបានធ្វើស្ទើរតែទាំងស្រុង ឬបានធ្វើទាំងស្រុង (៨១%-១០០%)"។

ជាលទ្ធផល ម្ចាស់ឆ្នោតបានផ្តល់ពិន្ទុទៅលើការសម្រេចបានរបស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗ ដែលម្ចាស់ឆ្នោតបានកំណត់កាលពីឆ្នាំ២០០៩ ដូចខាងក្រោម:

<table>
<tr><th colspan="2">លទ្ធផលនៃការវាយតម្លៃរបស់ម្ចាស់ឆ្នោតទៅលើការសម្រេចបាន របស់មន្ត្រីជាប់ឆ្នោតទៅលើចំនុចនីមួយៗនៃលក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាពទាំងដប់នៅក្នុងខេត្តព្រៃវែង</th></tr>
<tr><th>លក្ខខណ្ឌសន្ទស្សន៍នៃវិស័យអាទិភាព</th><th>លទ្ធផលនៃការផ្តល់ពិន្ទុដោយម្ចាស់ឆ្នោត</th></tr>
<tr><td>១) សុំកាត់បន្ថយរាល់បទល្មើសសង្គមដូចជា ឆក់ប្លន់ ល្បែងស៊ីសង ក្រុមក្មេងទំនើង គ្រឿងញៀន ជួញដូរកុមារ រំលោភកុមារ និងបទល្មើសនេសាទឆក់ត្រីអោយបាន៧០%នៃឆ្នាំ ២០០៩ នៅទូទាំងខេត្តព្រៃវែង ដោយចាប់ផ្តើមក្នុងឆ្នាំ២០០៩ តទៅ។</td><td>
</td></tr>
<tr><td>២) សុំឱ្យក្រសួងពាណិជ្ជកម្ម និងក្រសួងកសិកម្មជួយរកទីផ្សារសហគមន៍ ដើម្បីលក់ផលិតផលស្រូវ ពោត សណ្តែក ល្ង ចំនួន ៦កន្លែង សំរាប់ប្រជាពលរដ្ឋ នៅក្នុងស្រុកស៊ីធរកណ្តាល ស្រុកពាមរ ស្រុកបាភ្នំ ស្រុកកំពង់ត្របែក ស្រុកស្វាយអន្ទរ និង ក្រុងព្រៃវែង ឱ្យបាននៅក្នុងឆ្នាំ២០១១។<br><br>សុំឱ្យរាជរដ្ឋាភិបាល បន្ថយការយកពន្ធជីនាំចូលក្នុងប្រទេស ទាបជាង ៥០% នៃ តម្លៃបច្ចុប្បន្ន ចាប់ពីឆ្នាំ២០១០ តទៅ។ និងសុំឱ្យ មន្ទីរកសិកម្មជួយផ្តល់បច្ចេកទេសសមស្រប (ធ្វើជីកំប៉ុសនិងដាំបន្លែ)ដល់ប្រជាពលរដ្ឋ ក្នុងខេត្តព្រៃវែង។</td><td>
</td></tr>
</table>

៣) សុំប្រធានមន្ទីរសុខាភិបាលខេត្តព្រៃវែងជួយសំរួលដល់មន្ទីរពេទ្យ បង្អែកព្រៃវែង និងអ្នកលឿង ដូចជា:

- សុំឱ្យគ្រូពេទ្យព្យាបាលសិនទើបយកប្រាក់ជាក្រោយពីអ្នកជំងឺ
- សុំឱ្យមានថ្នាំគ្រប់គ្រាន់សំរាប់ព្យាបាល
- សុំកាត់បន្ថយសេវាព្យាបាលឱ្យបាន ៥០% នៃ ថ្លៃសេវាបច្ចុប្បន្ន ចាប់ពីចុងឆ្នាំ២០០៩ តទៅ។




៤) សុំឱ្យក្រសួងកសិកម្មសហការជាមួយ អង្គការនានា ដើម្បីបង្កើតសហគមន៍ ចិញ្ចឹមសត្វ ដូចជា គោ ជ្រូក ត្រី មាន់ ... និងផ្តល់ ពូជស្មៅ ចំណីសត្វ ដល់ [ សហគមន៍ ] នៅទូទាំងខេត្តព្រៃវែង ឱ្យបាននៅក្នុងឆ្នាំ២០១០។




៥) សុំអោយមានការពន្លឿនការអនុម័តច្បាប់ប្រឆាំងអំពើពុករលួយ ឱ្យបានត្រឹមឆ្នាំ២០១០។




៦) សុំឱ្យរាជរដ្ឋាភិបាលជួយជួសជុលផ្លូវកៅស៊ូ ប្រវែង ១០០ម ទទឹង ៨ម នៅភូមិលេខ៣ សង្កាត់កំពង់លាវ ខេត្តព្រៃវែង (ផ្លូវក្រោយវត្តសំសមី ចូលផ្សារ) ចាប់ផ្តើមពីដើមឆ្នាំ ២០១០ និងបញ្ចប់នៅឆ្នាំ២០១០។

- សុំជួសជុលផ្លូវគ្រួសក្រហមប្រវែង១៣គម ពីចំណុចភូមិពានា ឃុំអំពិលក្រៅ ដល់ភូមិដើមថ្នឹង ឃុំព្រៃដើមថ្នឹង ស្រុកស៊ីធរកណ្តាល ចាប់ពីឆ្នាំ២០១០ បញ្ចប់ ១០០% ក្នុង ឆ្នាំ២០១១។
- សុំជួសជុលផ្លូវគ្រួសក្រហម ប្រវែង ១៨០០ម ពីផ្លូវជាតិលេខ ១១ ក្នុងភូមិ និគមព្រះសុរាម្រឹតសីហនុ ឃុំបាបោង ស្រុកពាមរ ខេត្តព្រៃវែង ចាប់ពីឆ្នាំ២០១០ បញ្ចប់ ១០០% ក្នុងឆ្នាំ២០១១។



៧)  សុំរាជរដ្ឋាភិបាលជួយបង្កើតរោងចក្រកាត់ដេរឱ្យបានគ្រប់ស្រុក  (មួយស្រុក  មួយកន្លែង)  នៅក្នុងខេត្តព្រៃវែង ឱ្យបានចាប់ពី ឆ្នាំ២០១០ ដល់ឆ្នាំ ២០១២។




៨)  សុំឱ្យអភិបាលនៃគណៈអភិបាលខេត្ត បំពាក់អំពូលភ្លើងគ្រប់ដងវិថីទាំងអស់ នៅក្នុងក្រុងព្រៃវែង ខេត្តព្រៃវែង ចាប់ពីដើម ឆ្នាំ ២០១០ បញ្ចប់ក្នុងនៅចុងឆ្នាំ២០១០។




៩) ពេលបង្កើតរោងចក្របានហើយ សុំឱ្យរាជរដ្ឋាភិបាលជួយបង្កើនប្រាក់បៀវត្សរ៍ដល់កម្មកររោងចក្រ ឱ្យបានចំនួន ១០០ដុល្លារ ក្នុងមួយខែឡើងទៅ ចាប់ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១២។




១០)  សុំតម្លើងប្រាក់បៀវត្សរ៍ដល់មន្ត្រីរាជការ  (គ្រូបង្រៀន និងគ្រូពេទ្យ)  អោយបានចាប់ពី  ៤០ម៉ឺនរៀល  ឡើងទៅ ចាប់ផ្តើមនៅខែ១១  ឆ្នាំ២០០៩  នេះតទៅនៅទូទាំងខេត្តព្រៃវែង។




១១) **ចំនុចរួម:**

**តើអ្នកពេញចិត្តការអនុវត្តរបស់មន្ត្រីជាប់ឆ្នោតទៅលើលក្ខណ្ឌសន្ទស្សន៍ទាំង១០ កម្រិតណា?**



ការវាយតម្លៃនេះ ត្រូវបានធ្វើឡើងដោយម្ចាស់ឆ្នោតក្នុងវេទិកាម្ចាស់ឆ្នោតដែលរៀបចំដោយគណៈកម្មាធិការ **ខុមហ្វ្រែល** នៅថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០១០ នៅខេត្តព្រៃវែង ដោយមានកិច្ចសហការជាមួយសមាគមការពារសិទ្ធិមនុស្ស និងអភិវឌ្ឍន៍នៅកម្ពុជា (ADHOC), ពន្លឺនៃក្តីសង្ឃឹម (PNKS), អង្គការអតីតយុទ្ធជនអន្តរជាតិ (VI), និងអង្គការរក្សាការពារសិទ្ធមនុស្សនៅកម្ពុជា (VIGILANCE)។

*សម្រាប់ព័ត៌មានបន្ថែម  សូមទាក់ទង:*

លោក សុខ ពិទូរ្យ អ្នកសម្របសម្រួលផ្នែកអង្កេតខុមហ្វ្រែល ទូរស័ព្ទ: ០៨៩ ៥២៥ ៤៨៦